*សូមគោរព លោកអ្នកអាន ជាទីមេត្រី*

*ព្រះភិក្ខុ ងិន កេន គង់នៅប្រទេសបារាំង ចាប់ពីឆ្នាំ ១៩៩០ ។*

*ខ្ញុំបាទ អាន តាំងគីម បានរៀន ធម៌ព្រះពុទ្ធ ពីព្រះអង្គ ងិន កេន បានល្មមគ្រាន់ នឹងយកមកប្រតិបត្តិ ក្នុងជីវិតរស់នៅសព្វថ្ងៃ ដើម្បីជាសេចក្តីសុខខាងផ្លូវចិត្ត ។ ដោយខ្ញុំឃើញ កំណាព្យខ្លះ ដែលព្រះអង្គបានសរសេរនោះ អាចជាប្រយោជន៍ ដល់លោកអ្នកអានទាំងឡាយ ខ្ញុំ ក៏ដកស្រង់កំណាព្យទាំងនោះ ជា បន្ទាប់បន្ត មកជូនលោកអ្នក ដាក់ក្នុង* web-site*នេះ គ្រាន់ជាការពិចារណា ។*

*ព្រោះថាព្រះពុទ្ធ លោកមិនដែលបង្ខំយើង ឲ្យជឿនូវធម៌លោកដោយ ងងឹតលុងង់ មិនទាន់បានគិតពិចារណា ដោយប្រើ* **បញ្ញា** *នោះទេ ។ ពាក្យថា «បញ្ញា» មានន័យទូលាយ តែចំពោះការប្រតិបត្តិ មុនដំបូងគួរយល់ថា ធម៌ព្រះពុទ្ធ គឺជា ច្បាប់ធម្មជាតិ មានហេតុមានផល (មិនដែលមានផល ដោយគ្មានហេតុនោះទេ) ។ តើស្គាល់ច្បាប់ធម្មជាតិមានប្រយោជន៍អ្វីខ្លះ ? ស្គាល់ច្បាប់ធម្មជាតិ មានប្រយោជន៍ ត្រង់យើងស្គាល់សេចក្តីពិត យើងហ៊ានមើលការពិត មិនបញ្ឆោតខ្លួនឯង ពោលគឺហ៊ានទទួលការពិត ថ្វីបើការពិតនោះវាអាចជូរចត់យ៉ាងណាក៏ដោយ ។ អ្នកខ្លះសុខចិត្តរស់នៅក្នុងការប្រឌិត នឹកស្មានមិនហ៊ានប្រជល់មុខនឹងការពិតទេ ។*

*តែដោយយើងពុំអាចកែច្បាប់ធម្មជាតិបានដូចចិត្តបំណង ដល់ព្រិត្តការណ៍ធម្មជាតិនោះមកដល់ ក៏តាំងទ្រហោយំ ។ ហើយក៏ថា វាសនាអ្វីក៏អាក្រក់ម្ល៉េះ? តែបើយើងគោរពច្បាប់ធម្មជាតិ យើងខំរកមធ្យោយបាយដើម្បីដោះស្រាយ ឬកាត់បន្ថយ នោះយ៉ាងហោចណាស់ ក៏យើងមិនភ្ញាក់ផ្អើលខ្លាំងពេកនឹងព្រិត្តការណ៍នោះដែរ ។ នេះហើយប្រយោជន៍ស្គាល់ច្បាប់ធម្មជាតិ ។*

*ឧទាហរណ៍ ច្បាប់ធម្មជាតិមួយថា «កាលណាមានការកើត ត្រូវតែមានការស្លាប់ទៅវិញជាមិនខាន» អ្នកដែលសុខចិត្តទទួលច្បាប់នេះ ដល់ពេលមានការព្រាត់ប្រាស*

គ្រូសាបង្អួន ជាទី ស្រឡាញ់ អ្នកនោះ មិនសូវមានទុក្ខខ្លាំងដូចអ្នក ដែលមិនព្រម ទទួលយកច្បាប់ខាងលើនេះ ។

ហើយចំពោះច្បាប់ «ហេតុ ផល» ក៏ជាច្បាប់ធម្មជាតិដែរ មិនដែលយើងដាំដើមស្វាយ ហើយដល់ដើមស្វាយនោះចេញផ្លែ បានផ្លែ ក្រូចនោះទេ! ចំពោះច្បាប់ធម្មជាតិ បើដាំដើមស្វាយ បានផ្លែមក គឺ ផ្លែស្វាយ ។ យ៉ាងណាមិញ ដូច ធម៌ព្រះពុទ្ធចែងថា « ធ្វើល្អ បាន ល្អ » (ធ្វើបុណ្យ បានបុណ្យ) ឬ « ធ្វើអាក្រក់ បាន អាក្រក់ » (ធ្វើបាប បានបាប) ។ តែជួនកាល អំពើដែលគេធ្វើនោះ វាពុំទាន់ឲ្យផល ហើយ អ្នកដែលកំពុងតែធ្វើអំពើអាក្រក់នោះ កំពុងតែសោយនូវផលនៃអំពើល្អដែលខ្លួនបានធ្វើពីមុនមក ។

ឧទាហរណ៍ មួយដ៏ជាក់ស្តែង គឺនៅប្រទេសបារាំង មានភ្នាក់ងារ នគរបាលម្នាក់ដោយគាត់បានធ្វើអំពើល្អស្មោះត្រង់ហើយមានសមត្ថភាពទៀត គាត់បានឡើងជា មេនគរបាលមួយរូប មានមុខងារធំជាងគេក្នុងក្រុង បារីស ប្រទេសបារាំង ។ គេពុំបានដឹងថា នគរបាលនោះបានធ្វើអំពើពុករលួយចាប់តាំងពីពេលណាមកទេ ។ ស្រាប់តែថ្ងៃមួយ បែកការណ៍ រដ្ឋអំណាច ក៏ព្យួរដំណែងដែលគាត់កំពុងកាន់ ។ នេះបានន័យថា មុននឹងបែកការណ៍ មេនគរបាលនោះ បានសោយនូវបុណ្យស័ក្តិនៃអំពើល្អដែលអ្នកនោះធ្លាប់បានធ្វើ ។

ព្រះពុទ្ធ លោកគ្រាន់តែបង្ហាញផ្លូវ ឲ្យយើងដើរ បើផ្លូវនោះយើងដើរទៅ បានសេចក្តីសុខចម្រុងចម្រើន នោះយើងក៏យកទៅ តែបើសិនជាយើងដើរតាមផ្លូវនោះ មិនបានសេចក្តីសុខទេ នោះយើងកុំយក ។ រួមសេចក្តីទៅ ព្រះអង្គ ឥតមានបង្ខំយើង ឲ្យត្រូវតែធ្វើតាមព្រះអង្គទេ ពោលគឺព្រះអង្គគោរពសេរីភាព របស់យើងគ្រប់ៗគ្នា។ តែយើងគួរតែប្រយ័ត្នដែរ ព្រោះមានអ្នកខ្លះ យកធម៌ព្រះពុទ្ធទៅក្លែងក្លាយ ដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន ក៏មានដែរ ហេតុនេះហើយបានជាខ្ញុំថា ធម៌ព្រះពុទ្ធពិត ។ នៅពេលទេសនាម្តងៗ ព្រះសង្ឃ លោកតែងតែ មានថេរដីកាថា ព្រះអង្គនឹងសម្តែងធម៌ព្រះពុទ្ធ (ពោលគឺមិនមែនជាធម៌របស់ ព្រះសង្ឃជាអ្នកសម្តែងនោះទេ) ៕